Ind 04A

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ CID : [redacted]

លេខ LA : [redacted]

លេខ SA : ✓.......................................

# កិច្ចសន្យាចងការប្រាក់

រវាង

១. ភាគីឱ្យខ្ចី : ស្ថាបនា លីមីតធីត សាខាខេត្តបន្ទាយមានជ័យ តំណាងពេញច្បាប់ដោយលោក ហាក់ សុផល នាទីជា ប្រធានសាខា តទៅនេះ ហៅថាភាគី "ក"

និង

២. ភាគីខ្ចីចងការ : ឈ្មោះ.....[redacted].......ភេទ.[redacted]..ថ្ងៃខែឆ្នាំកំណើត.[redacted]. សញ្ជាតិ [redacted]...

☑ អត្តសញ្ញាណប័ណ្ណ ☐ សៀវភៅគ្រួសារលេខ[redacted]...ចុះថ្ងៃខែឆ្នាំ[redacted] ចេញដោយ[redacted]...

និងឈ្មោះ .....[redacted]..............ភេទ[redacted] ថ្ងៃខែឆ្នាំកំណើត[redacted] ត្រូវជា[redacted].... តទៅនេះហៅថាភាគី "ខ"

ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងចុះហត្ថលេខាលើកិច្ចសន្យាខ្ចីចងការប្រាក់ ដោយអនុវត្តរាល់ប្រការដូចខាងក្រោម :

**ប្រការ ១ :**

## អំពីលក្ខខណ្ឌរួម

លើមូលដ្ឋាននៃពាក្យសុំខ្ចីចងការ សេចក្តីណែនាំស្តីពីគោលការណ៍ និងលក្ខខណ្ឌនៃការឱ្យខ្ចីចងការភាគី "ក" យល់ព្រមអោយភាគី "ខ" ខ្ចីចងការ ហើយភាគី "ខ" ក៏ព្រមទទួល និងសន្យាសងមកភាគី "ក" វិញជាដាច់ខាត នូវប្រាក់ខ្ចីចងការនេះតាមចំនួន និងរាល់លក្ខខណ្ឌ ដែលបានព្រមព្រៀងគ្នាដូចតទៅនេះ :

១.១ ក្រោមការដាក់បញ្ចាំ ដើម្បីធានាបំណុលទាំងដើមទាំងការ

- ចលនៈ ឬអចលនវត្ថុរបស់ឈ្មោះ.....ដាក់ គឹមសៀ.....និង .....ដាក់ គុណ.................ដែលមានបញ្ជាក់ក្នុងកិច្ចសន្យាដាក់បញ្ចាំ ។
- ចលនៈ ឬអចលនវត្ថុរបស់ឈ្មោះ..........✓..........និង ..........✓..........ជាអ្នកយល់ព្រមដាក់បញ្ចាំជំនួសភាគី "ខ" ដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យាដាក់បញ្ចាំ ។

១.២ ប្រាក់ខ្ចីចងការដែលភាគី "ខ" បានទទួលចំនួនជាលេខ : 12,000,000៛ ចំនួនជាអក្សរ.....ដប់ពីរលានរៀលគត់..... ត្រូវបានអនុញ្ញាតឱ្យបើកផ្ទាល់ ឬ ដកចេញពីគណនីរបស់ភាគី "ខ" ។

១.៣ រយៈពេលចងការ : .......12.......ខែ គិតចាប់ពីថ្ងៃទទួលប្រាក់តទៅ ឬ គិតចាប់ពីថ្ងៃផ្ទេរចូលគណនីរបស់ភាគី "ខ" ។

១.៤ របៀបសងបំណុល : អនុវត្តតាមតារាងកាលវិភាគសងប្រាក់ ដោយបង់ប្រាក់ផ្ទាល់ ឬ កាត់ចេញពីគណនីរបស់ភាគី "ខ" ។

១.៥ អត្រាការប្រាក់ : .......2.5.......ភាគរយក្នុង១ខែ ។

១.៦ កំរៃសេវារដ្ឋបាលដែលត្រូវបង់មុនពេលបើកប្រាក់ចំនួន.....15,000៛..... ។

១.៧ ទីកន្លែងបង់ប្រាក់ និង ឧបសម្ព័ន្ធ :

- ត្រូវបង់ប្រាក់នៅ ☑ ការិយាល័យ ស្ថាបនា លីមីតធីត ☐ សហគមន៍
- កាលវិភាគសងប្រាក់ កិច្ចសន្យាដាក់បញ្ចាំ ប័ណ្ណចំណាយប្រាក់អោយខ្ចី ឬប័ណ្ណដកប្រាក់ជាឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ។

១.៨ ភាគី "ខ" សន្យាថានឹងមិនប្រើប្រាស់ឥណទានដែលទទួលបានពីភាគី "ក" ធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន សង្គម និងសកម្មភាពទាំងឡាយដែលហាមឃាត់ដោយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២:** **អំពីលក្ខខណ្ឌពិសេស**

ក្នុងករណីដែលភាគី "ខ" មិនបានអនុវត្តតាមការសន្យាសងប្រាក់ដើម និងការប្រាក់តាមកាលកំណត់ តាមចំនុច ១.២ ១.៣ ១.៤ ១.៥ ១.៦ ១.៧ ១.៨ នៃប្រការ១ ខាងលើនេះ ភាគី "ខ" យល់ព្រមអោយភាគី "ក" អនុវត្តវិធានការរបស់ក្រុមហ៊ុន ស្ថាបនា លីមីតធីត ដូចតទៅ :

២.១ ក្នុងករណីកូនបំណុលយឺតយ៉ាវមិនបានសងប្រាក់ទាន់ពេលវេលាតាមតារាងកាលវិភាគសងប្រាក់ កូនបំណុលសុខចិត្តបង់ប្រាក់ពិន័យចំនួន [illegible]............ ក្នុងមួយថ្ងៃ ដោយគណនាតាមចំនួនថ្ងៃដែលបានខកខាន។ ក្នុងករណីនេះដែរភាគី "ក" មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះសាកសួរព័តិមានអំពីការយឺតយ៉ាវដើម្បីរកដំណោះស្រាយ។

២.២ ក្នុងករណីដែលកូនបំណុលបង្វែរប្រាក់កម្ចីឱ្យទៅម្ចាស់បំណុលវិញទាំងអស់ ឬសងផ្តាច់មុនកាលកំណត់ក្នុងរយៈពេលចាប់ពីពាក់កណ្តាលនៃកិច្ចសន្យាឡើងទៅរហូតដល់បញ្ចប់នៃកិច្ចសន្យា ការប្រាក់ត្រូវគិតទៅតាមចំនួនថ្ងៃដែលបានប្រើប្រាស់ជាក់ស្តែង វៀរលែងតែបង់ផ្តាច់មុនពាក់កណ្តាលនៃកិច្ចសន្យា គឺគិតការប្រាក់តាមខែ ដែលត្រូវបង់ការប្រាក់តាមតារាងកាលវិភាគសងប្រាក់ បន្តបន្ទាប់រហូតដល់ពាក់កណ្តាលនៃកិច្ចសន្យា។

២.៣ ក្នុងករណីដែលខកខានមិនបានសងបំណុលតាមកំណត់តាមចំណុច ១.៤ កន្លងផុតរយៈពេលមួយខែ (១ខែ) ភាគី "ខ" យល់ព្រមប្រគល់ទ្រព្យដាក់បញ្ចាំជូនភាគី "ក" តែមួយគត់ដើម្បីចាត់ចែងលក់ឡាយឡុងយកប្រាក់មកសងបំណុលដែលជំពាក់ទាំងស្រុងរួមទាំងប្រាក់ដើម ប្រាក់ការ និងប្រាក់ពិន័យផ្សេងទៀត។ ក្រោយពីការទូទាត់បំណុលជូនភាគី "ក" ទាំងស្រុងហើយ ថវិកាដែលនៅសល់ត្រូវប្រគល់ជូនភាគី "ខ"។ បញ្ជាក់ភាគីដទៃទៀត រួមទាំងម្ចាស់បំណុលផ្សេងទៀតពុំមានសិទ្ធិរាំងភាគី "ក"ក្នុងការលក់ឡាយឡុងទ្រព្យដាក់បញ្ចាំដូចមានរៀបរាប់ក្នុងកិច្ចសន្យាដាក់បញ្ចាំបានទេ។ ករណីមិនទាន់បានសងគ្រប់ភាគី "ខ" ត្រូវមានកាតព្វកិច្ចសងបំណុលដែលនៅសល់បន្ថែមទៀតរហូតទាល់តែគ្រប់ចំនួន។

២.៤ ក្នុងករណីដែលចំនុច ១.៨ នៃប្រការ១ មិនត្រូវបានគោរព ភាគី "ក" មានសិទ្ធិគ្រប់គ្រាន់ក្នុងការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ដោយតំរូវឱ្យភាគី "ខ" សងត្រឡប់មកវិញនូវប្រាក់ដើមទាំងអស់រួមជាមួយនឹងការប្រាក់ រហូតដល់ពាក់កណ្តាលនៃកិច្ចសន្យា ឬគិតតាមការប្រើប្រាស់ជាក់ស្តែង បើភាគី "ខ"បានប្រើប្រាស់លើសពីពាក់កណ្តាលនៃកិច្ចសន្យា។

**ប្រការ៣:** **អំពីលក្ខខណ្ឌអវសាន្ត**

ភាគី "ក" និងភាគី "ខ" សន្យាគោរពយ៉ាងម៉ឺងម៉ាត់តាមរាល់ប្រការនៃកិច្ចសន្យាខាងលើ។ ក្នុងករណីមានការអនុវត្តផ្ទុយ ឬដោយរំលោភលើលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះ ភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ រាល់សោហ៊ុយទាក់ទងក្នុងការដោះស្រាយ ឬវិវាទជាបន្ទុករបស់ភាគី ដែលរំលោភបំពានលើកិច្ចសន្យា។

កិច្ចសន្យានេះត្រូវបានធ្វើឡើង ដោយមានការព្រមព្រៀងពិតប្រាកដ និង ដោយសេរី គ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទទួលប្រាក់ ឬ ផ្ទេរចូលគណនីរបស់ភាគី "ខ" តទៅ។

កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន ២ច្បាប់ (១ច្បាប់ដើម និង ១ច្បាប់ថតចំលង) ដើម្បីតំកល់ទុកនៅ :

- ភាគី "ក" ......................................................................០១ ច្បាប់ដើម
- ភាគី "ខ" ......................................................................០១ ច្បាប់ថតចំលង

ថ្ងៃទី...13....ខែ....03.......ឆ្នាំ..2013........

ស្នាមមេដៃស្តាំ ភាគីខ្ចីចងការ ភាគី "ខ" | តំណាងភាគីឱ្យខ្ចីចងការ ភាគី "ក"

សាក្សី | អ្នករួមខ្ចី | អ្នកសុំខ្ចី | [illegible] ហត្ថលេខា និង ត្រា

ព្រះរាជាណាចក្រកម្ពុជា
ស្ថាបនា លីមីតធីត
SATHAPANA LIMITED
សាខាខេត្តបន្ទាយមានជ័យ

ហេង-ឫទ្ធា

[redacted]

Print Date : 3/16/2013
Time : 9:23:36 AM
Currency : KHR

# ស្ថាបនា លីមីតធីត

## កាលវិភាគបង់ប្រាក់

សាខា បន្ទាយមានជ័យ

លេខសំគាល់អតិថិជន : [redacted]
អតិថិជនឈ្មោះ :
ភេទ :
អាសយដ្ឋាន :

លេខគណនីប្រាក់កម្ចី : [redacted]
ចំនួនប្រាក់កម្ចី : 12,000,000 រៀល
រយៈពេលខ្ចីប្រាក់ : 366 ថ្ងៃ
អត្រាការប្រាក់ : 2.50 %
ខុនទី : 05
កាលបរិច្ឆេទបើកប្រាក់ : 16-03-2013

| លើកទី | កាលបរិច្ឆេទ បង់ប្រាក់ | ប្រាក់ត្រូវបង់ | ប្រាក់ដើម | ការប្រាក់ | សមតុល្យប្រាក់ដើម |
|---|---|---|---|---|---|
| 1 | 18-04-13 ព្រហស្បតិ៍ | 330,000 | 0 | 330,000 | 12,000,000 |
| 2 | 16-05-13 ព្រហស្បតិ៍ | 280,000 | 0 | 280,000 | 12,000,000 |
| 3 | 17-06-13 ច័ន្ទ | 320,000 | 0 | 320,000 | 12,000,000 |
| 4 | 16-07-13 អង្គារ | 290,000 | 0 | 290,000 | 12,000,000 |
| 5 | 16-08-13 សុក្រ | 310,000 | 0 | 310,000 | 12,000,000 |
| 6 | 16-09-13 ច័ន្ទ | 310,000 | 0 | 310,000 | 12,000,000 |
| 7 | 16-10-13 ពុធ | 300,000 | 0 | 300,000 | 12,000,000 |
| 8 | 20-11-13 ពុធ | 350,000 | 0 | 350,000 | 12,000,000 |
| 9 | 16-12-13 ច័ន្ទ | 260,000 | 0 | 260,000 | 12,000,000 |
| 10 | 16-01-14 ព្រហស្បតិ៍ | 310,000 | 0 | 310,000 | 12,000,000 |
| 11 | 17-02-14 ច័ន្ទ | 320,000 | 0 | 320,000 | 12,000,000 |
| 12 | 17-03-14 ច័ន្ទ | 12,280,000 | 12,000,000 | 280,000 | 0 |
| | | 15,660,000 | 12,000,000 | 3,660,000 | |

### ម៉ោងធ្វើការ

- ថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សុក្រ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល
- ថ្ងៃ សៅរ៍ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១១:០០ ព្រឹក

**ភ្នាក់ងារឥណទានឈ្មោះ : ឆាន់ ហ្វួយី**

**ទូរស័ព្ទលេខ** : (855) 096 8499 666

សូមផ្តល់យោបល់ អំពីការបំរើសេវាកម្មរបស់យើងខ្ញុំតាមរយៈ
ទូរស័ព្ទលេខ: 097 957 6666

ថ្ងៃ សៅរ៍ ទី 16 ខែ មិនា ឆ្នាំ 2013

**ហត្ថលេខាបេឡាករ** **ស្នាមមេដៃអតិថិជន**

**ប្រពន្ធ** **ប្តី**

**លាន សុនីតា** **ចាច់ គមសៀ** **ចាច់ គុង**